# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៦ ... សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការលុបកិច្ចព្រមព្រៀងវិនិយោគ និង អាជ្ញាប័ណ្ណធ្វើអាជីវកម្មព្រៃសម្បទាន
## របស់ក្រុមហ៊ុន GRAND ATLANTIC TIMBER SDN BHD

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងព្រៃសម្បទាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ

## សម្រេច

**ប្រការ ១:** លុបកិច្ចព្រមព្រៀងវិនិយោគ និង អាជ្ញាប័ណ្ណធ្វើអាជីវកម្មព្រៃសម្បទានរបស់ក្រុមហ៊ុន GRAND ATLANTIC TIMBER SDN BHD ដែលពុំបានគោរពតាមល័ក្ខខ័ណ្ឌ នៃកិច្ចព្រមព្រៀង នូវផ្ទៃដីព្រៃសម្បទានចំនួន ៣៦៥.៥០០ ហ.ត ស្ថិតនៅខេត្តកំពង់ធំ ក្រចេះ កោះកុង និង ពោធិសាត់ ។

**ប្រការ ២:** ព្រៃសម្បទានដែលដកហូតពីក្រុមហ៊ុនខាងលើ ត្រូវរក្សាទុកជាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ។

**ប្រការ ៣:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្ដីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តដែលពាក់ព័ន្ធ និង ក្រុមហ៊ុនដែលមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្ដីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ